# ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


០៥-០១-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០១០០/០០១ ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ ឯក ជូននាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ១

០៨-០១-២០០០ -ព្រះរាជក្រឹត្យ នស/រកត/០១០០/០០២ ដាក់ឲ្យចូលនិវត្តន៍មន្ត្រីអតីតរដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី និងអគ្គនាយកនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ២


## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៥-០១-២០០០ -អនុក្រឹត្យលេខ ០១/អនក្រ.បក ស្តីពីការបដិសេធមិនទទួលស្គាល់សិទ្ធិរបស់ តំណាងសាលាខេត្តសៀមរាប ក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវិទ្យា អប្សរា ៤

០៥-០១-២០០០ -អនុក្រឹត្យលេខ ០២/អនក្រ.បក ស្តីពីការលុបចោលដីកាលេខ ១៩១ ចសរ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩ ៥

០៤-០១-២០០០ -អនុក្រឹត្យលេខ ០១/អនក្រ.តត ស្តីពីការតែងតាំងនាយកនគរបាលជាតិ ៦

០៥-០១-២០០០ -អនុក្រឹត្យលេខ ០២/អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧

០៥-០១-២០០០ -អនុក្រឹត្យលេខ ០៣/អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨

០៥-០១-២០០០ -អនុក្រឹត្យលេខ ០៤/អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩


## III- ការិយាល័យក្រសួង

### ១- ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

#### ប្រកាស


០៤-០១-២០០០ - ប្រកាសលេខ ០០២/ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១១

០៤-០១-២០០០ - ប្រកាសលេខ ០០៣/ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១២

ក ២

## ១- ឱស្ថការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

### ប្រកាស


០៦-០១-២០០០ - ប្រកាសលេខ ០២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ តាកាង ក្នុងឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ១៣

០៦-០១-២០០០ - ប្រកាសលេខ ០៣ អយក.ប្រក ស្តីពីការតម្លើងអនុវិទ្យាល័យ ជីភូ ទៅជាវិទ្យាល័យ ជីភូ ស្ថិតក្នុងឃុំព្រែកម្លេស ស្រុកស្វាយទាប ខេត្តស្វាយរៀង ១៤

០៦-០១-២០០០ - ប្រកាសលេខ ០៤ អយក.ប្រក ស្តីពីការតម្លើងអនុវិទ្យាល័យ ត្រាំខ្នារ ទៅវិទ្យាល័យត្រាំខ្នារ ស្ថិតក្នុងឃុំសូភី ស្រុកបាទី ខេត្តតាកែវ ១៥

០៦-០១-២០០០ - ប្រកាសលេខ០៥ អយក.ប្រក ស្តីពីការតម្លើងអនុវិទ្យាល័យ ថ្នល់បំបែក ទៅជាវិទ្យាល័យ ថ្នល់បំបែក ស្ថិតក្នុងឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ១៧

០៦-០១-២០០០ - ប្រកាសលេខ ០៦ អយក.ប្រក ស្តីពីការបើកវិទ្យាល័យ សិរីមង្គល ក្នុងឃុំរកាកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល ១៩

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស/រកត/០១០០/០០១**

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សំណើនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០០

**ត្រាស់បង្គាប់**

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម ៖

១- ឧត្តមសេនីយ៍ទោ **មល់ រឿប** អត្តលេខ ០០០០៤៣ បច្ចុប្បន្ននាយរងសេនាធិការចំរុះ នាយក នាយកដ្ឋាន ស្រាវជ្រាវចារកិច្ច នៃអគ្គបញ្ជាការដ្ឋាន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ។

២- ឧត្តមសេនីយ៍ទោ **ជា សារ៉ា** អត្តលេខ ០០០១៨៣ បច្ចុប្បន្ន នាយរងសេនាធិការចំរុះ នាយក ទីចាត់ការកណែទម្រង់ នៃអគ្គបញ្ជាការដ្ឋាន ។

៣- ឧត្តមសេនីយ៍ទោ **គួច ស៊ីផាន** អត្តលេខ ០០០០៥១ បច្ចុប្បន្ន នាយរងសេនាធិការចំរុះ នៃអគ្គបញ្ជាការដ្ឋាន ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយ និងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ព្រះហស្ថលេខា និង ហត្ថលេខា

**អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន ទៀ បាញ់**

★★★

## **ព្រះរាជក្រឹត្យ នស/រកត/០១០០/០០២**

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់អនុក្រឹត្យលេខ ៦២/អនក្រ. ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា ១ .-** ដាក់ឱ្យចូលនិវត្តន៍មន្ត្រីអតីតថ្នាក់រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី និងអគ្គនាយក នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំនួន ០៤រូប ដែលមានឈ្មោះដូចខាងក្រោម ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ តទៅ ៖

១- ឯកឧត្តម **នុត ណារ៉ាង** អតីត រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២- ឯកឧត្តម **ឆេង ផុន** អតីត រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

៣- ឯកឧត្តម **ជ័យ សោភា** អតីត អនុរដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

៤- ឯកឧត្តម **ណុប តួន** អគ្គនាយក ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# II- អនុក្រឹត្យ

## អនុក្រឹត្យលេខ ០១/អនក្រ.បក

## ស្តីពីការបដិសេធមិនទទួលស្គាល់សិទ្ធិរបស់តំណាងសាលាខេត្តសៀមរាប ក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវិទ្យាអប្សរា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បទបញ្ជាលេខ ៣០/បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រាជរដ្ឋាភិបាល
- យោងការខ្វះលក្ខណៈសម្បត្តិគតិយុត្តក្នុងសមត្ថកិច្ចចុះហត្ថលេខាតំណាងឲ្យសាលាខេត្តសៀមរាប
- យោងតាមការអនុវត្តន៍គោលការណ៍រដ្ឋបាលទូទៅ

### សម្រេច

មាត្រា ១._ បដិសេធមិនទទួលស្គាល់សិទ្ធិរបស់លោក ជា ភក្តី តំណាងសាលាខេត្តសៀមរាបក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវិទ្យាអប្សរា ធ្វើនៅខេត្តសៀមរាប ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមូលហេតុ ពុំមានលក្ខណៈសម្បត្តិគតិយុត្តក្នុងសមត្ថកិច្ចនិងមិនស្របទៅនឹងបទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ២ ._ ចាត់ទុកជាមោឃៈរាល់សិទ្ធិនិងបទបញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចសន្យាជួលរវាង លោក ជា រក្ខិ ជាមួយក្រុមហ៊ុនវិទ្យាអប្សរាលីមីធីត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដែលនាំអោយកិច្ចសន្យាក្នុងនេះ គ្មានសុពលភាព ។

មាត្រា ៣._ ប្រគល់ការថែរក្សាសណ្ឋាគារអប្សរា ដែលមានទីតាំងនៅខាងកើតមហាសណ្ឋាគារអង្គរ លើផ្ទៃដីចំនួន ៥.៧៩៧ ម៉ែត្រក្រឡា ឲ្យអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប ។

មាត្រា ៤._ រាជរដ្ឋាភិបាលមិនទទួលខុសត្រូវលើការខូចខាតកន្លងមក ដែលមិនស្របនឹងនីតិវិធីស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ៥._ រាល់បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប ក្រុមហ៊ុនវិទ្យាអប្សរាលីមីធីត និងគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ០២/អនក្រ.បក**

**ស្តីពីការលុបចោលដីកាលេខ ១៤១ សសរ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៥**

**របស់សាលាខេត្តសៀមរាប**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីណែនាំអនុវត្តលេខ ០៣សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុវត្តន៍គោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី
- យោងតាមការអនុវត្តន៍គោលការណ៍រដ្ឋបាលទូទៅ

**សំរេច**

មាត្រា ១ .- ត្រូវបានលុបចោលលិខិតលេខ ១៥១សសរ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៥ របស់គណៈខេត្តសៀមរាប ស្តីពីការប្រគល់ដីធ្លីមួយកន្លែងជូនលោក តាន់ ឆាយ្ល ដែលមានទីតាំងស្ថិតនៅប៉ែកខាងលិចផ្លូវទៅអង្គរវត្តទល់មុខគោលតេព្វកោសល្យ វិក្រឹតការខេត្ត ដោយមូលហេតុការប្រគល់ដីនេះធ្វើឡើងក្រៅវង្វង់សមត្ថកិច្ចសំរេចរបស់ខេត្ត និងដោយបំពានបទបញ្ញត្តិ និងគោលបទរដ្ឋបាល ដែលនាំអោយបណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ គសរ.០០០៦៦៨ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ គ្មានសុពលភាព ។

មាត្រា ២.- ប្រគល់ការថែរក្សាទីតាំងនេះ ជូនអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប ។

មាត្រា ៣.- រាល់បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងលោក តាន់ ឆាយ្ល ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ០១/អនក្រ.តត**

**ស្តីពីការតែងតាំងនាយនគរបាលជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១**.- ត្រូវបានតែងតាំងលោកវរសេនីយ៍ឯក សៅ វ៉ានី ជាប្រធាននាយកដ្ឋាន នគរបាលសេដ្ឋកិច្ចនៃក្រសួងមហាផ្ទៃ ។

**មាត្រា ២**.- រាល់បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនិងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣**.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ០២/អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៥ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ. ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**មាត្រា ១ ._** តែងតាំងលោក **កែប ចន** ជាអគ្គនាយកសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ស្របតាមមាត្រា ៩ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរហៅថា (កាំសាប) ។

**មាត្រា ២._** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ០៣/អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ,
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញសំណើរបស់ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

**សំរេច**

មាត្រា ១ ._ តែងតាំងមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន២រូប ដូចមានរាយនាមខាងក្រោម :

១- លោក តែវ កុសល ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល

២- លោក សរ សាមេធា ជាប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ០៤/អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងអនុក្រឹត្យលេខ ០៧ អនក្រ. ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីការប្តូរឈ្មោះវិទ្យាស្ថានបច្ចេកទេសកសិកម្ម
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១ ._** តែងតាំងមន្ត្រី ០៣រូប ជាព្រឹទ្ធសាស្ត្រាចារ្យ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម :

១- លោក **ខៅ ម៉ុនថាន** ជាព្រឹទ្ធសាស្ត្រាចារ្យ មហាវិទ្យាល័យវិទ្យាសាស្ត្រវិស្វកម្មកសិកម្ម

២- លោក **ឈួន ប៊ូរិន** ជាព្រឹទ្ធសាស្ត្រាចារ្យ មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល

៣- លោក **ទន មុនិន្ទ** ជាព្រឹទ្ធសាស្ត្រាចារ្យ មហាវិទ្យាល័យវិទ្យាសាស្ត្ររុក្ខកម្ម

**មាត្រា ២._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

# III- ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងព័ត៌មាន

## ប្រកាស

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០០*

**ប្រកាសលេខ ០០២ ពម.ប្រក**

**ស្ដីពីការតែងតាំងមន្ត្រីរាជការ**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា
- ពិនិត្យឃើញគុណសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

**សំរេច**

ប្រការ ១ : តែងតាំងលោក **ជ័យ សោភា** ជាអនុប្រធាននាយកដ្ឋានព័ត៌មានផ្សាយទៅបរទេស ។

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលសោតទស្សន៍, លោកនាយកខុទ្ទកាល័យ, ឯកឧត្តមអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា, លោកប្រធាននាយកដ្ឋានបុគ្គលិក, លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ-ហិរញ្ញវត្ថុ និងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**លី ឡាយស្រេង**

★★★

*រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៥*

**ប្រកាសលេខ ០០៣ ពម.ប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

**សំរេច**

**ប្រការ ១ :** តែងតាំងលោក ញ៉ែម សុគន្ធថុល ជាអនុប្រធាននាយកដ្ឋានផលិតកម្មវិធីចំណេះដឹងទូទៅ ។

**ប្រការ ២ :** ឯកឧត្តមអគ្គនាយករដ្ឋបាលសោតទស្សន៍, លោកនាយកខុទ្ទកាល័យ, ឯកឧត្តមអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា, លោកប្រធាននាយកដ្ឋានបុគ្គលិក, លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ-ហិរញ្ញវត្ថុ និងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**លី ធ្លាយស្រេង**

★★★

## ២- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០០

### ប្រកាសលេខ ០២ អយក.ប្រក
### ស្តីពីការបើកអនុវិទ្យាល័យ តាមាង ក្នុងឃុំកោះរកា
### ស្រុកកំពង់សៀម ខេត្តកំពង់ចាម

***

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទអ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលាបង្រៀនមធ្យមសិក្សាកំរិត១-កំរិត២ ។
- យោងលើលិខិតស្នើសុំរបស់ សហគមន៍ ឃុំកោះរកា ចុះថ្ងៃទី៨ ខែមករា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

### សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ តាមាង ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គភាពលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយកនាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និង កីឡា និងប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តកំពង់ចាម និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០០

## ប្រកាសលេខ ០៣ អយក.ប្រក

## ស្ដីពីការពង្រីក អនុវិទ្យាល័យ " ជីគួ " ទៅជាវិទ្យាល័យ "ជីគួ" ស្ថិតនៅក្នុងឃុំ ច្រកម្ទេស ស្រុកស្វាយទាប ខេត្តស្វាយរៀង

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។

- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទអ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលាបង្រៀនមធ្យមសិក្សាកំរិត១-កំរិត២ ។
- យោងលិខិតស្នើសុំលេខ ៥២២ អយក.មចម.ពស របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តស្វាយរៀង ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ " ជីភូ " បច្ចុប្បន្នទៅជា វិទ្យាល័យ "ជីភូ" ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា និងប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តស្វាយរៀង និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

បាត់លេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០០

## ប្រកាសលេខ ០៨ អយក.ប្រក
## ស្តីពីការពង្រីក អនុវិទ្យាល័យ " ត្រាំខ្នារ " ទៅជាវិទ្យាល័យ " ត្រាំខ្នារ "
## ស្ថិតនៅក្នុងឃុំ សូទី ស្រុកបាទី ខេត្តតាកែវ

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញគោលការណ៍ណែនាំលេខ ៦៦ អរ.គទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកគណៈបង្រៀនមធ្យមសិក្សាកម្រិត១-កម្រិត២ ។
- យោងលិខិតស្នើសុំលេខ ៨៩ អយក.គមត.ម របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៩ ដោយមានការយល់ព្រមពីអភិបាលខេត្តតាកែវ ។
- តាមការយល់ព្រមរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ " ត្រាំខ្នារ " បច្ចុប្បន្នទៅជា វិទ្យាល័យ " ត្រាំខ្នារ " ចាប់ ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកម្នាក់ និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍ របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា និងប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០០

## ប្រកាសលេខ ០៥ អយក.ប្រក

## ស្តីពីការពង្រីក អនុវិទ្យាល័យ " ថ្នល់បំបែក " ទៅជាវិទ្យាល័យ " ថ្នល់បំបែក " ស្ថិតនៅក្នុងឃុំ ជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលាបង្រៀនមធ្យមសិក្សាកម្រិត១-កម្រិត២ ។
- យោងលិខិតស្នើសុំលេខ ៩២ អយក.តមចម របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តតាកែវ ។
- តាមសេចក្តីឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ "ថ្នល់បំបែក" បច្ចុប្បន្នទៅជាវិទ្យាល័យ " ថ្នល់បំបែក " ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា និងប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តតាកែវ និងនាយកវិទ្យាល័យសោភី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

បណ្ឌលេខា និង ត្រា

អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០០

## ប្រកាសលេខ ០៦ អយក.ប្រក

## ស្ដីពីការបើក វិទ្យាល័យ " សិរីមង្គល " ក្នុងឃុំ កោះកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៩ ស្ដីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។

- បានឃើញសារាចរណែនាំលេខ ៦៦ អវ.គទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២ ។
- យោងលើលិខិតស្នើសុំរបស់ សហគមន៍ប៉ុរកាពោង២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយបើកវិទ្យាល័យដែលមានឈ្មោះថា : វិទ្យាល័យសិរីមង្គល ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកម្នាក់ និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា និងប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តកណ្តាល និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

★★★